# CITY OF LONG BEACH

POLICE DEPARTMENT

400 WEST BROADWAY • LONG BEACH • CALIFORNIA 90802 • (562) 570-7260 • FAX (562) 570-7114

Robert G. Luna

*អគ្គមេបញ្ជាការ*


## របៀបនៃការតវ៉ារបស់ប្រជាជន

### ការបង្ហាញណែនាំជាដំណឹង

អគ្គមេបញ្ជាការនៃក្រសួងប៉ូលិសមានភារកិច្ចតម្រូវតាមច្បាប់ទៅលើដំណើរការនៃការស៊ើបអង្កេតចំពោះសេចក្ដីតវ៉ាទាំងឡាយដែលកើតមានឡើងចេញមកពីសមាជិករបស់សាធារណជនទៅលើបុគ្គលិកនៃក្រសួងប៉ូលិស ។

បុគ្គលិកនៃក្រសួងប៉ូលិសរបស់ទីក្រុងឡងប៊ីចត្រូវបានជ្រើសរើសបំរើកិច្ចការយ៉ាងហ្មត់ចត់ជាទីបំផុត ព្រមទាំងមានការហ្វឹកហ្វឺនដើម្បីបំពេញមុខនាទីទៅតាមវិជ្ជាជីវៈដែលជាមោទនភាពមួយ ។ ក៏ប៉ុន្តែ នេះគឺជាក្រសួងដ៏ធំមួយ អ្វីវាតែងតែកើតមានឡើងចំពោះការសម្រេចចិត្តផ្សេងៗគ្នាទៅលើកិច្ចការ ។ ការតវ៉ាទាំងឡាយដែលចោទប្រកាន់លើការអនុវត្តន៍មិនត្រឹមត្រូវចំពោះបុគ្គលិកណាមួយគឺតម្រូវឱ្យមានការស៊ើបអង្កេតយ៉ាងត្រឹមត្រូវ ក្នុងគោលបំណងដើម្បីឱ្យក្រសួងមានសច្ចភាពនិងជំនឿទំនុកចិត្តអំពីសំណាក់របស់សាធារណជន ។

ការចាត់ចែងលើផ្នែករដ្ឋបាលនៃការអនុវត្តន៍ច្បាប់ឱ្យបានត្រឹមត្រូវគឺជាមធ្យោបាយដើម្បីឱ្យក្រសួងប៉ូលិសមានដំណើរការតាមវិជ្ជាជីវៈដ៏ប្រពៃ ។ ក្រសួងប៉ូលិសនៃទីក្រុងឡងប៊ីចបានខឹតខំធ្វើយ៉ាងណាដើម្បីឱ្យក្រសួងរបស់យើងបំរើនូវសេវាដ៏ឧត្ដុង្គឧត្ដមគ្រប់ពេលវេលានិងទៅអនាគត ។

**ដំណើរការ**

ប្រជាជនទាំងអស់មានសិទ្ធិតវ៉ាទៅលើបុគ្គលិកទាំងឡាយនៅក្នុងក្រសួងប៉ូលិស ។ ការតវ៉ាអាចប្រាប់ទៅកាន់អ្នកទទួលខុសត្រូវ ឬទៅកាន់កិច្ចការអន្តរក្រសួង (Internal Affairs Division) ។ ការតវ៉ាអាចធ្វើឡើងបានដោយចូលខ្លួនមកផ្ទាល់, តាមទូរស័ព្ទ, តាមអ៊ីម៉េល ឬតាមរយៈនរណាម្នាក់ផ្សេងដែលមិនទាក់ទងក្នុងករណីដែលបានកើតឡើង ។ ការតវ៉ាក៏អាចធ្វើបានដោយអនាមិក ។ ក្រសួងនឹងចម្លងលើសេចក្ដីតវ៉ារបស់អ្នកដែលបានចូលខ្លួនផ្ទាល់ដោយមានចុះនូវហត្ថលេខាប្រគល់ជូនទៅអ្នកវិញ ។ ចំពោះករណីផ្សេងយើងនឹងផ្ញើជាសំបុត្រដើម្បីជំរាបជូនជាដំណឹង ។

**ខណៈពេលដែលទទួលបាននូវការតវ៉ា, ករណីទាំងឡាយដូចតទៅដែលត្រូវធ្វើ:**

1. ការតវ៉ានឹងបញ្ជូនទៅកាន់ Internal Affairs Division ដែលជាកន្លែងចុះនូវលេខសំណុំរឿងសម្រាប់ធ្វើការស៊ើបអង្កេត ។
2. បុគ្គលដែលធ្វើការតវ៉ាគេនឹងផ្ញើសំបុត្រជូនជាដំណឹងចេញពីក្រសួងដោយបញ្ជាក់ជូនផងដែរនូវលេខនៃសំណុំរឿង ។
3. នៅពេលបញ្ចប់ការស៊ើបអង្កេត សំណុំរឿងនឹងបញ្ជូនទៅកាន់ជំនួយនៃអគ្គមេបញ្ជាការ និង/ឬ អគ្គមេបញ្ជាការដើម្បីធ្វើការសម្រេច ។
4. បន្ទាប់ពីបានពិនិត្យចប់សព្វគ្រប់ពីក្រសួងប៉ូលិសហើយគេនឹងបញ្ជូនទៅកាន់ក្រុមឯករាជមួយដែលមានឈ្មោះថា Citizen's Police Complaint Commission (CPCC) ។ គេនឹងផ្ញើសំបុត្រទៅអ្នកដើម្បីជំរាបជាពត៌មានទៅលើករណីនៃការពិនិត្យទៅលើសំណុំរឿងដែលបានធ្វើរួចរាល់នោះហើយ ។

ចំណាំ: ជាមធ្យមដំណើរការនៃការស៊ើបអង្កេតលើសេចក្ដីតវ៉ាអាចប្រព្រឹត្តទៅក្នុងរយៈវេលាចន្លោះពី ៣ ទៅ ៦ ខែ ។

## ដាក់ពាក្យតវ៉ារបៀបណា

**នេះជាពត៌មានសំខាន់ៗនៅពេលទៅធ្វើការដាក់ពាក្យតវ៉ាៈ**

- ឈ្មោះមន្ត្រីប៉ូលិសនិងភិនភាគ, លេខអត្តសញ្ញាណ, និងលេខឡាន ប្រសិនជាមាន
- ឈ្មោះសាក្សីនានា, អស័យដ្ឋាន និងលេខទូរស័ព្ទ
- ភ័ស្តុតាងអ្វីដែលអ្នកយល់ថាសំខាន់ក្នុងការតវ៉ាដូចជាកូពីនៃសំបុត្រផាកពិន័យ,រូបថត ។ល ។
- ប្រសិនបើអ្នកមានរបួស,ជាការសំខាន់អ្នកត្រូវចូលតវ៉ាឱ្យបានឆាប់រហ័សដែលអាចធ្វើបានដោយមានរូបថត និងកំណត់ត្រាពីកន្លែងពិនិត្យព្យាបាល

ពត៌មាននេះអាចទទួលបានជាភាសាដទៃទៀតអាចចូលទៅកាន់បណ្តាញ

www.longbeach.gov/police/info/complaints/default.asp

*ឬលោកអ្នកក៏អាចតវ៉ាផ្ទាល់តាមរយៈអ៊ីម៉េលទៅកាន់*

**Internal.Affairs@longbeach.gov**

ការិយាល័យស៊ើបអង្កេតខឹតខំយ៉ាងណាដើម្បីរកឱ្យបានឃើញត្រឹមត្រូវពិតប្រាកដក្នុងស្ថានការណ៍និមួយៗ ។ ប្រសិនបើអ្នកតវ៉ាយល់ថាការស៊ើបអង្កេតមិនបានធ្វើនោះទេ លោកអ្នកអាចទាក់ទងទៅកាន់ការិយាល័យនៃអង្គការនានាដែលមានឈ្មោះដូចខាងក្រោមនេះ :

| | |
|---|---|
| ក្រសួងប៉ូលិសទីក្រុងឡុងប៊ីច<br>400 West Broadway<br>Long Beach, CA 90802<br>(562) 570-7260 | ក្រុមប្រឹក្សានៃគណកម្មការទទួលការតវ៉ារបស់ប្រជាជន<br>Long Beach City Hall 13th Floor<br>333 West Ocean Boulevard<br>Long Beach, CA 90802<br>(562) 570-6891 |
| District Attorney's Office របស់ខោនទី( ស្រុក)<br>Los Angeles County<br>275 Magnolia Avenue, Suite 3195<br>Long Beach, CA 90802<br>(562) 247-2000 | ក្រសួងប៉ូលិសទីក្រុងឡុងប៊ីច<br>INTERNAL AFFAIRS DIVISION<br>400 West Broadway<br>Long Beach, CA 90802<br>(562) 570-7343 |
| Attorney General's Office របស់រដ្ឋ<br>State of California<br>Attn: Public Inquiry Unit<br>P.O. Box 94425<br>Sacramento, CA 94244 | Grand Jury<br>Los Angeles County<br>B-303 Criminal Courts Building<br>210 West Temple<br>Los Angeles, CA 90012 |
| Federal Bureau of Investigation របស់សហព័ន្ធ<br>501 W. Ocean Boulevard<br>Suite #7370<br>Long Beach, CA 90802<br>(562) 432-6951 | |

ពត៌មាននេះអាចទទួលបានជាទម្រង់ផ្សេងទៀតដោយហៅទៅកាន់បុគ្គលិករដ្ឋបាលតាមរយៈលេខ (562) 570-7120.